គ្រប់គ្នារត់ចេញផុយពីខ្ញុំ។ នៅទីនេះបានស្ងប់ស្ងាត់ទៅវិញបណ្ដើរៗសល់តែខ្ញុំ ដែលប្រហែលជាត្រូវរង់ចាំក្រុមជំនួយមកដល់សិន.....ប៉ុន្តែប្រសិនបើមកយឺតពេលពេល?

ស្នូរក្មេងស្រែកយំរន្ធត់លាន់មកមួយរំពេចស្ងាត់។

ព្រះ! នៅក្នុង នៅមានកុមារត្រូវជាប់គាំង?

ខ្ញុំឈានចូលសន្សឹមៗ.....ដៃក្ដាប់អាវុធភ្នែករំពៃ....

និយាយតាមត្រង់ទៅ ប្រសិនបើជនរងគ្រោះមិនមែនកុមារ ខ្ញុំតក់ក្រហល់មិនភ្លេចភ្លាំងតួនាទីម្ល៉ឹងទេ។

«អ្នកណានៅក្នុង?»

ស្ងាត់!

ខ្ញុំទាញកាំភ្លើងភ្ជង់ចុះក្រោមដោយដៃទាំងពីរយ៉ាងជាប់ម៉ឺង ហើយចុះជណ្ដើរទៅតាមអាគារវែងជ្រៅដែលស្ងាត់ជ្រងំ។ វត្តមានភ្លាមៗនៃការស្រែកនិងរលត់លឿនពេក ធ្វើឱ្យខ្ញុំពិបាករកប្រភពវា។

សំឡេងស្អកមួយ រសាត់ចេញមកបន្តិចពីបន្ទប់នៅខាងមុខជួរទៅឆ្វេងដៃនៃដំណើររបស់ខ្ញុំ។ ខ្ញុំរត់ទៅស្រាលស្ងើក ហើយគាំងជាមួយស្លាកសញ្ញានៅលើជញ្ជាំងខាងក្រៅទ្វារដាក់ថា ថ្នាក់របស់កញ្ញាឡាសុន ខារ៉េន ថ្នាក់ទីបី។

«ចប់ហើយដុកទ័រ!»

ខ្ញុំរអ៊ូម្នាក់ឯងបេះដូងលោតដូចជារឺស័ររលាក់។

«អ្នកណានៅក្នុង? ចេញមក!»

មិនឮឆ្លើយខ្ញុំលើកជើងធាក់។ អ្វីដែលខ្ញុំបានរកឃើញក្រោយកម្លាំងទ្វាររបើកផ្ទូងផាំង អាចធ្វើឱ្យខ្ញុំឈឺគ្រុន។ កញ្ញាឡាសុនពិតជាមានវត្តមែនតែក្នុងអាការៈមិនល្អទេ។ សម្រស់ជាព្រះនាង បានរលាយបាត់ បន្សល់នូវសរសៃសក់រញ៉េរញ៉ៃបំប៉ើងពេញមុខ បញ្ចេញតែផ្នែកខ្លះនៃភ្នែកក្រហមៗរបស់នាង។

អាក្រក់ណាស់! នាងមិនប្រក្រតីហើយ!

គ្រាប់ភ្នែកបែបនេះ បានរំឭកខ្ញុំអំពីបុរសម្នាក់ដែលខ្ញុំបានជួបតទល់ ខណៈគាត់ឆ្លួតកម្រោលនៅក្នុងពេទ្យព្រោះត្រូវឆ្កែខាំហើយពេទ្យជួយបន្សាបមិនទាន់។

រឿងដែលធុញបំផុតពេលនេះ គឺនាងមានក្មេងប្រុសតូចម្នាក់នៅក្នុងដៃនាង។ ក្មេងនេះប្រហែលជាមានអាយុមិនលើសប្រាំបីឆ្នាំទេ ត្រូវនាងក្រសោបចងលើបានដោយប្រើដៃនាងកាន់តែម្ខាងផុតដីរួចដែរ? នាងបានកម្លាំងពីណាមក?

«Nikes» ឈ្មោះក្មេងនៅលើអាវ។

«ដាក់គេចុះ!»

ខ្ញុំនិយាយទាំងភ្ជង់ជាប់។

ក្មេងនៅតែត្រូវក្របួចតេកតោកព្យួរជើងពីលើឥដ្ឋ។ ទឹកមុខស្លេកយំមិនចេញនិងទន់ខ្សោយសម្លឹងមកខ្ញុំសុំការសង្គ្រោះ។

«ដាក់ Nikes ចុះឡាសុន ក្រែងគេជាសិស្សជាទីស្រឡាញ់ហ្អី?»

ខ្ញុំនិយាយក្នុងសំឡេងលួងបំផុត មិនបានស្រែកទេ ប៉ុន្តែខ្ញុំក៏មិនខ្សឹបដែរ។ ស្ងប់ស្ងាត់ នាងគ្រហឹមនិងហិតចុះឡើងដូចក្របីហិតញី។ ពពុះលើមាត់របស់នាងមិនមែនជារឿងល្អទេ។ នៅកន្ទុយភ្នែកខ្ញុំ ខ្ញុំក្រឡេកទៅមើលសាកសពមួយផ្សេងទៀតដែលនៅក្បែរនោះ។ ធំណាស់មិនមែនជាកូនក្មេងទេ ប៉ុន្តែអាចទាយដឹងថា ជាបុរសម្នាក់។ ប្រហែលជាអ្នកមើលការខុសត្រូវបរិវេណនេះឬនាយកសាលា។ គាត់មិនបានកម្រើកទេ សូម្បីតែដកដង្ហើមក៏អត់ ឈាមប្រឡាក់ពេញខ្លួនទៅហើយ។ ពេលនេះ ខ្ញុំយល់ស្រេចថា ហេតុអ្វីបានជាដៃជើងរបស់កញ្ញា Larson មានឈាមអន្លើៗ។

ខ្ញុំបានគោះលើកៃ ប្រសិនចាំបាច់ខ្ញុំនឹងប្រើកាំភ្លើងរបស់ខ្ញុំការពារអាយុកុមារនេះ ពីជំងឺឆ្កែឆ្កួត។ ខ្ញុំត្រូវច្បាស់ថា ឡាសុនលែងជាខ្លួននាងទៀតហើយ។

«ដាក់ចុះ!» សំឡេងរបស់ខ្ញុំតឿៀតជាងមុនព្រោះតែខ្ញុំខាំមាត់ខឹងចិត្តនឹងរឿងនាងខាំបុរសនេះដល់ស្លាប់។

ឡាសុន អង្រួនក្បាលរបស់នាងដូចជាឆ្កែដែលរង្គើមិនឈប់និងលៀនអណ្ដាតស្រក់ទឹកភ្នែក។ ភាពច្របូកច្របល់ក្នុងកិរិយានាង មិនមែនជាប្រក្រតីភាពនៃមនុស្សធម្មតាទៀតទេ។

ខ្ញុំញ័រពីលើរាងកាយដល់ក្រោម ទប់ខ្លួនឯងមិនចង់ជាប់។

នាងគ្រហឹម....ហ្វូមៗ ចេញពីមាត់របស់នាង បណ្ដាលឱ្យខ្ញុំសង្កេតឃើញស្នាមប្រឡាក់ឈាមនៅលើធ្មេញ។

ខ្ញុំលូកជើងឈានទៅមុខ ឯនាងញាប់ញ័រ ទាញក្មេងទៅកាន់តែជិត។ កុមារបិទភ្នែកទម្លាក់ដៃទន់ខ្លួន។ គេសន្លប់ហើយ។

ខ្ញុំស្បថថា  នាងកំពុងគ្រហឹមតែស្ទេញធ្មេញលើក្រោមដូចញញឹមទឹកកកគ្មានបេះដូង។ វិញ្ញាណរបស់សត្វ បង្ហាញឡើងក្នុងភ្នែករបស់កញ្ញានេះជំនួសឱ្យស្មារតីមនុស្ស។ ខណៈខ្ញុំញ័រចុងកាំភ្លើង នាងងើបក្បាលមករឹប ដូចជាចង់ត្របាក់យកហែកបំពង់ករបស់ក្មេងក្នុងដៃ តែសំឡេងកាំភ្លើងបានបន្លឺឡើងពេញបន្ទប់និងបញ្ឈប់នាង.....ក្បាលរបស់នាងរើបថយចេញពីក្មេង ខណៈដែលគ្រាប់កាំភ្លើងបានឆក់ខ្ទាតខួរក្បាលរបស់នាង នាងដួលស្រុញចុះ....អរគុណព្រះ ដែលក្មេងនោះសន្លប់រេលលើសាកសពនាងឡាសុន។ មុនពេលដែលអ្នកអានយល់ខុស ខ្ញុំចង់បញ្ជាក់ថា មិនមែនខ្ញុំបាញ់នាងទេណា៎។

## ខ្ញុំមិនបានកេះកៃទេ!

ខ្ញុំបានដើរចច្រប់ជុំវិញចៅហ្វាយរបស់ខ្ញុំ គឺលោកនាយ ឃ្លីដេ ចនស្តុន Clyde Johnston ។

«ជេស៊ីឯងបាញ់សង្គ្រោះក្មេងនោះឬកែ?» គាត់រអ៊ូរទាំក្នុងសំនៀងជនជាត់អាមេរិកកាត់ឥណ្ឌា ដែលពេលញាប់ញ័រគាត់កាន់តែរដឹក។ ការគិតអំពីអនាគតនៃអាជីពរបស់ខ្ញុំ     ធ្វើឱ្យការនិយាយរបស់គាត់រញ៉េរញ៉ៃ។ ខ្ញុំប្រញាប់រាយការណ៍អធិប្បាយលម្អិត៖

«មិនមែនទាំងអស់ទាន! ពេលត្រចៀកហ៊ឹងឮកម្រិតAនាំសំឡេងផ្ទុះ ខ្ញុំរត់ពេញបន្ទប់រកក្មេងប្រុសនោះ មកតែគេនៅសន្លប់ពីលើរាងកាយឡាសុនដែលនាងដួល!»

«ក្បាលរបស់នាងឡាសុនមានរន្ធដ៏ធំមួយ! ទំនងជា Guess.44 Magnum គឺជាកាំភ្លើងដ៏មានឥទ្ធិពលបំផុតនៅក្នុងពិភពលោក» មេខ្ញុំនិយាយបន្ថែម «មួយគ្រាប់ទេស្ទើរតែផ្លុំខួររបស់នាងចេញអស់ពីក្បាល! អូខេ មិនមែនកាំភ្លើងឯងទេ ជេស៊ី»។

នេះគឺ«លើសហើយ»សម្រាប់ខ្ញុំមកឈរស្តាប់។ ខ្ញុំបានសុំចេញទៅមាត់ទ្វារស្រូបខ្យល់អាកាសបន្តិចជាមួយនឹងក្រសែភ្នែកតាមដានក្មេងត្រូវបានក្រុមសង្គ្រោះរុញឡើងឡាន។ គេថយ៉ាងណាក៏មិនបានយូរទេ ទោះបីខ្ញុំមិនចង់ក៏ខ្ញុំបានវិលត្រលប់ទៅកន្លែងកើតហេតុវិញ។ លោកនាយ Clyde របស់ខ្ញុំដូចជារកបានភស្តុតាងនិងអ្វីៗគ្រប់យ៉ាងនៅក្រោមការគ្រប់គ្រងអស់ហើយ។

តំបន់ Miniwa មួយនេះ ជាសហគមន៍តូចមួយ ចែករំលែកក្នុងក្រុង Clearwater ឆ្លងកាត់បឹងវែង ព្រៃ ជាមួយនិងទីក្រុងតូចៗជាច្រើនទៀត។ ពេលខ្ញុំចូលទៅក្នុងបន្ទប់ដដែលកាលណា លោកនាយ Clyde សួរឡើងភ្លាម៖

«ប្រាប់មក Jessie ម៉េចបាននាងមកនៅចំកណ្ដាលព្រឹត្តិការណ៍រញ៉េរញ៉ៃនេះ?»

«ខ្ញុំកំពុងតាមដានករណីមួយ»។

គាត់បានងាកមកដោយភាពងឿងឆ្ងល់។

«សំណុំរឿងអី? មួយណា?»

«គ្រោះថ្នាក់ចរាចរណ៍ដែល កញ្ញា Larson បានបុកឆ្កែចចកនៅលើភ្នំ»

គាត់ដូចមិនបានទទួលព័ត៌មាននេះសោះឡើយ។ ខ្ញុំបានរៀបរាប់គ្រប់យ៉ាងជាព័ត៌មានលម្អិតយ៉ាងឆាប់រហ័សដល់គាត់។

«ចចក?»

មេខ្ញុំញាក់ជើងច្បួតមុខមាត់គិត។ គាត់រអ៊ូបញ្ឆោន់ពីលើសេចក្ដីរាយការណ៍របស់ខ្ញុំ

«នាងដេញក្លិនឈាម ទាំងយប់ ទាំងគ្មានសញ្ញាសត្វនេះ បន្ទាប់មកកញ្ញា Larson បានចេញចោលគ្លីនីក? មនុស្សប្រុសអាក្រាត?» គាត់បញ្ឈប់ត្រង់ណោះព្រោះលោកនាយ Clyde នឹងមិនចាប់អារម្មណ៍រឿងនេះដូចយើងស្រីៗទេ។

«ពួកកាសែតជុំវិញប៉ូលិសទៀតហើយ!»

ខ្ញុំដកដង្ហើមធំ។ ពួកគេនោះមិនសូវធ្វើអ្វីល្អទេ ប៉ុន្តែនិយាយដើមបំផុតឧប្បត្តិហេតុនានា ឱ្យទៅជាព្រឹត្តិការណ៍ដ៏សំខាន់ដេញសេរីជាអ្វីមួយពួកគេថ្មីក។

«នឹងមានខ្មាន់កាំភ្លើងពូកែៗច្រើនគ្នា សម្រុកទៅក្នុងព្រៃ ស្វែងរកឆ្កែចចកដ៏ឃោរឃៅនោះ!»

លោកនាយខ្ញុំឧទានឡើង។ មិនថាតែប៉ុននោះគាត់លើកបន្ថែម៖

«យើងនឹងមានបញ្ហា ព្រោះការសម្លាប់មួយនេះនឹងដុតឱ្យពលរដ្ឋភ័យស្លន់ស្លោ! ប៉ូលិសត្រូវដោះស្រាយបានមុនពួកព័ត៌មានដែលនិយមផ្លុំរឿងត្រឹមតែផ្សេងឱ្យទៅជាភ្លើង!»

មេខ្ញុំរអ៊ូដោយអារម្មណ៍ទទួលខុសត្រូវរបស់គាត់។ គាត់ចាក់មកទៀតមិនឈប់៖

«បើស្តាប់តាមនាង មានផ្កែវង្វេង ហើយប្រហែលជាមនុស្សវង្វេងទៀតផង!»

ខ្ញុំគិតថាគាត់សំដៅបុរសដែលអាក្រាតនោះ។

«ចាស៎ពិត!» ខ្ញុំរអ៊ូទាំងសម្លឹងមើលសាកសព។

មុននឹងគាត់បាននិយាយអ្វីបន្តទៀត កម្លាំងជំនាញផ្នែកព្រហ្មទណ្ឌនិងមន្ត្រីប៉ូលិសផ្នែកអធិការកិច្ចពីរនាក់ទៀតបានមកដល់ ហើយពួកគេចាប់ផ្តើមធ្វើការ។ ខ្ញុំបានផ្តល់របាយការណ៍លម្អិតតាមការពិតគ្រប់យ៉ាង ដែលនាំឱ្យខ្ញុំត្រូវបានដោះលែងវិលទៅសម្រាកវិញនៅក្រោយពីសាកសួរកន្លះម៉ោង។

មួយចប់តាមផ្លូវវិលទៅផ្ទះ ខ្ញុំឆ្ងល់នូវរឿងជាច្រើន។ សូម្បីប្រះមកគេង ប៉ុន្តែអ្វីមួយនៅបន្តចោទឡើងក្នុងមនសិការរបស់ខ្ញុំ គោះខ្ញុំឱ្យស្វាងមិនងងុយ។ ការចងចាំដ៏ច្របូកច្របល់បានបន្តបង្ហាញឡើងចុះចុះឡើង សូម្បីពេលងោកបន្តិចក៏ក្នុងសុបិនរបស់ខ្ញុំ ឮការសន្ទនាអំពីជាតិពុលនាចង្កូមផ្កែ ថ្នាំផ្កែឆ្កួត កោសល្យវិច្ច័យវេជ្ជសាស្ត្រលើសាកសពនាងឡាសុន និងបុរសដែលមានពាក់ក្រវិលពណ៌មាសអាក្រាតកាយក្នុងព្រៃ ចុងក្រោយរឿងតាមប្រមាញ់សត្រូវជាចចក។

អ៊ឺះ.....

ខ្ញុំដូចស្តាប់ឮការស្រម៉ុកមួយអឺះចុងក្រោយរបស់ខ្លួនឯង ក៏បះដៃភ្ញាក់ឡើង។ ពន្លឺព្រះខែពណ៌សប្រាក់នារាត្រីកាលពេញបូណ៌មីកណ្តាលអាធ្រាត្រកំពុងចាំងជះរះលម្អពេញគ្រែរបស់ខ្ញុំ។

ហ្នឹង!

ខ្ញុំភ្លេចទាញវាំងននត្របកខាងក្នុងបិទ។

ម្យ៉ាងដែរ ឆ្លងកាត់រឿងជាច្រើន ខ្ញុំអាចដេកនៅពេលថ្ងៃនិងដឹងខ្លួនមកធ្វើការពេលកណ្តាលយប់? ទើបតែលើកដៃញីថ្ងាស ប្រុងថាដើរទៅកិនគ្រាប់កាហ្វេ សំណួរមួយបានស្វាគមន៍ខ្ញុំ.....

«ហេតុអ្វីនាងពុលលឿនម្លេះ? លែងជាមនុស្សរលីង?»

ដើរទាំងល្ងើយចូលទៅផ្ទះបាយ បើកម៉ាស៊ីនឆុងកាហ្វេ រុញពែងរបស់ខ្ញុំដាក់លើថាសរហូតដល់វាពេញ ឈ្ងុយពេញបន្ទប់ទើបខ្ញុំឈប់គិត។ ក្រេបដំបូងស្វាងដែរ។ ស្រឡះភ្នែកទាំងកណ្តាលយប់ តែបើកវាំងននស្រទាប់ក្រៅខ្វាក សម្លឹងទៅដានផ្លូវរទេះភ្លើងនាជាន់ខាងក្រោមឆ្ងាយ ចិត្តខ្ញុំបន្តវិលវល់គិត
។

«ប្រសិនបើគ្រូក្មេង ឡាសុន ខារ៉ែន ពិតជាបើកឡានបុកឆ្កែចចកនោះ វាគួរតែរាបដីហើយ! ម្ដេចក៏ខ្ញុំរកឃើញស្លាកអលង្ការនាងនៅឆ្ងាយពីកន្លែងឡានមានឧប្បត្តិហេតុ?»

ការពន្យល់សមស្របតែមួយគត់ គឺស្លាកបន្តោងនោះមិនមែនរបស់នាង ឬវាជាអលង្ការរបស់ឆ្កែចចក?

សំខាន់ត្រង់មានប្រលាក់ឈាមទៀត!

ខ្ញុំបាននឹកដល់កំណត់ត្រាដែលខ្ញុំបានអានកាលនៅគ្លីនីក ខណៈពេលដែលខ្ញុំរង់ចាំគ្រូពេទ្យមកនិយាយនឹងខ្ញុំ។ នាងឡាសុនធ្លាប់ប្រាប់តាមកំណត់ហេតុនោះថា ឆ្កែចចកកំពុងប្រដេញនឹង...អ្វីមួយបានជ្រុលមកប៉ះទង្គិចនឹងឡាននាង នាងស្មានថាវាស្លាប់ ក៏បើកទ្វារហើយក៏ត្រូវខាំ....

ខ្ញុំបានសម្រេចចិត្តស្វែងរកអត្ថន័យនៃវត្ថុនោះ ហើយនឹងចង់ដឹងថា អ្នកណាខ្លះចូលចិត្តពាក់អលង្ការ។ ចុចបើកទូរសព្ទ ខ្ញុំឃើញព័ត៌មានថា គ្រូស្ការវ័យក្មេងឈ្មោះឡាសុន មានរោគឆ្កែឆ្កួតមុនស្លាប់។ ហួសចិត្តណាស់ ជំងឺឆ្កែឆ្កួត ត្រូវការពេលពីពីរអាទិត្យទៅបីខែដើម្បីចេញរោគសញ្ញា តែឡាសុនទើបតែរងគ្រោះលើភ្នំមិនដល់មួយថ្ងៃកន្លះនៅឡើយ។

ដោយសារយ៉ាងនេះ ព្រឹកឡើងភ្លាម អ្នកដែលខ្ញុំទៅអង្គុយចាំគឺ វេជ្ជ.Prescott Bozeman ។ លេខាគាត់គ្រវីក្បាលដូចដឹងមុនថាខ្ញុំនឹងមក«រករឿង»។ នាងប្រាប់ខ្ញុំថាគាត់មិននៅទេ និងមិនដឹងថាពេលណាទើបគាត់មកការិយាល័យនេះឡើយ។ ខ្ញុំទប់ទល់នឹងចំណោទគួរឱ្យឈឺក្បាលទាំងអស់នោះទៀតមិនបានទេ ការទ្រាំរបស់ខ្ញុំកាន់តែលេចបាត់ ការចង់ដឹងចង់សួរនាំកំពុងផ្ទុះឡើងយ៉ាងធ្ងន់ធ្ងរ។ ខ្ញុំស្ទុះក្រោកហើយសួរៈ

«តើនរណាជាអ្នកចេញប្រកាសរឿងជនរងគ្រោះឆ្លងជំងឺឆ្កែឆ្កួត?»

«ខ្ញុំមិនអាចនិយាយបានទេ។» លេខាឆ្លើយយ៉ាងសឹមរឹម។

«ចឹងប្រាប់មក ពេលណាដែល Dr Bozeman ព្រមមកធ្វើការងាររបស់គាត់?»

បបូរមាត់របស់នាងខ្ទឹបបង្ហាញភាពមិនចូលចិត្តខ្ញុំ និងមិនឆ្លើយអ្វីគ្រប់យ៉ាង។ ចាំអស់ចិត្តមិនបានផល ខ្ញុំចេញពីការិយាល័យ នោះវិញបន្ទាប់ពីទុកឈ្មោះ លេខទូរសព្ទ។

ធាតុបន្ទាប់នៅក្នុងរបៀបវារៈរបស់ខ្ញុំ គឺការស្វែងរកអ្នកជំនាញមើលស្លាកអលង្ការនៃជនជាតិដើមអាមេរិក។ នេះអាចថា ពិបាកជាងអ្វីដែលខ្ញុំបានគិតឬធ្លាប់ជួបពីមុន។ ដូច្នេះខ្ញុំនឹកឃើញដល់ហ្សេដាស្ត្រីប៉ូលិសឯកោនិងមានបទពិសោធច្រើន រឿងព្រះចន្ទនិងចាមពលបិសាចអីនោះ។

«កូនស្រីឯងទៅសួរពួកមានប្រភពដើមមកពីឥណ្ឌាទៅ! ស្លាកនេះពួកនោះតែងពាក់! មានមនុស្សម្នាក់នៅ សាកលវិទ្យាល័យ Miniwa»

តាមពាក្យហ្សេដាប្រាប់មកសាកលវិទ្យាល័យ Miniwa ស្ថិតនៅលើវាលទំនាបដ៏ធំបំផុតមួយនាត្រើយម្ខាងឆ្ងាយនៃបឹង Clearwater ល្បីថា មានក្រុមអ្នកប្រាជ្ញឥណ្ឌាក្នុងស្រុកជាច្រើន និងមួយចំនួនតូចមកពីកុលសម្ព័ន្ធផ្សេងៗ បានក្លាយជាសាស្ត្រាចារ្យសិល្បៈនិងប្រវត្តិសាស្ត្ររយៈពេលខ្លីដូចជាសម្រាប់មួយឆមាស ឬពីរឆមាសចេញចូលឆ្លាស់វេនគ្នា។ មិនដឹងអារម្មណ៍អីទេ បើកឡានមកដល់កន្លែងនេះ ខ្ញុំមានទំនុកចិត្តថា នឹងរកបាននរណាម្នាក់ ស្គាល់ប្រវត្តិឬព័ត៌មានអំពីផ្លាកអលង្ការនៅក្នុងហោប៉ៅរបស់ខ្ញុំនេះ។

បានដូចចិត្ត សួរនាំគេមិនដល់ពេលប្រាំនាទីផង ខ្ញុំត្រូវបានដឹកនាំទៅកាន់ការិយាល័យរបស់លោក William Cadotte ដែលជាសាស្ត្រាចារ្យមកពីរដ្ឋ Minnesota និងជាអ្នកជំនាញខាងប្រវត្តិជនជាតិដើមអាមេរិក។ បុរសនេះពេលឮឈ្មោះកាលណាខ្ញុំក៏ចាំបានភ្លាមថា ស្ថិតក្នុងបញ្ជីរបស់លោកនាយ Clyde សម្រាប់តាមដាន ព្រោះគាត់មានទំនាក់ទំនងជាមួយពួកមន្តអាគមខ្មៅ។

ខ្ញុំបានដើរតាមការនាំផ្លូវទៅកាន់ការិយាល័យមួយនៅចុងប៉ូចមានស្លាកថា William បិទជាប់នឹងជញ្ជាំង។ ទ្វារបានរបើកចូលក្នុង.....ខ្ញុំក្រឡេកមើលកន្លែងជះក្លិនមកនោះ ព្រោះទីនេះមានទំហំប៉ុនទូដាក់ឥវ៉ាន់ ចាស់ មានកៅអីនិងមានគំនរសៀវភៅ បំណែកតូចៗនៃឈើ ដែក ក៏ដូចជាថ្មត្រូវបានរាយប៉ាយពាសពេញផ្ទៃតបន្ទប់។ ដោយសារទីនេះមិនមានបង្អួច បន្ទប់មានក្លិនស្អុយ ហើយសភាពពន្លឺគឺងងឹត។

«នឹកខ្ញុំហ្មែន?»

សំឡេងបានរុញខ្ញុំឱ្យសឹងធាក់ថយក្រោយ។ ជាសំឡេងមនុស្សអាក្រាតថ្ងៃមុនគ្រាន់តែពេលនេះគេស្លៀកពាក់ ហើយកំពុងញញឹមលើកចិញ្ចើមឱ្យខ្ញុំ។

«មនុស្សអាក្រាតរបស់ខ្ញុំបានក្លាយមកជា បណ្ឌិត Will Cadotte? ហើយ....គេដូចជានៅចំណាំខ្ញុំ? ចំណាំច្បាស់ៗទៀត?

ខ្ញុំឃើញមិនបាច់ពិនិត្យនីបក្រវិលមាសដេញភ្លើងផ្លេកៗលើត្រចៀកគេពេលគេផ្អៀងក្បាល។

មិនត្រឹមពាក់ខោអាវជាអ្នកចេះដឹងថែមទាំងមានពាក់វ៉ែនតាទៀត។ គ្មានអីគួរឱ្យឆ្ងល់ទេ ដែលខ្ញុំមើលគេសឹងចាំមិនបាន ស្គាល់តាមរយៈសំនៀងនិយាយតែប៉ុណ្ណឹង។ ពេលនេះគេចាស់ជាងមុន ឆ្លាតជាងមនុស្សអាក្រាតនោះ ហើយស៊ិចស៊ីជាងពេលដែលឈរស្រាតនៅក្រោមពន្លឺព្រះចន្ទទៅទៀត។

«បណ្ឌិត Cadotte មែនទេ?»

«ទេ»

ខ្ញុំលើកចិញ្ចើម។

«ខ្ញុំជា William Cadotte គ្រាន់តែថា ខ្ញុំមិនមែនជាវេជ្ជបណ្ឌិតទេ»

«ខ្ញុំមានរឿងខ្លះចង់ពិភាក្សា....សុំយោបល់!»

«តើខ្ញុំអាចជួយអីបាន?» គេសួរមកវិញធ្វើហី តែសព្ទសំឡេងដូចពេលយប់មិញដដែល មិនខ្លាំង មិនជ្រាយ នៅតែមានថាមពលទាក់ទាញ។

ខ្ញុំអាចធុំក្លិនពីខ្លួនគេជាសម្ងាត់ ក្លិនដូចគ្នាពីយប់មិញ គឺក្លិននៃខ្យល់ ដើមឈើ និងផ្កាឬស្មៅព្រៃ។ ខណៈខ្ញុំស្ងាត់មាត់ គេក៏សម្លឹងមកខ្ញុំដោយចេតនា ហាក់ដូចជាគិតថា ខ្ញុំស្ងៀមព្រោះភ្លឹកចាប់អារម្មណ៍លើគេ។ សង្ឃឹមថាគេមើលមិនដឹងគំនិតរវើរវាយរបស់ខ្ញុំធ្លាក់ចូលទៅក្នុងទីជ្រៅនៃរឿងភេទសម្ព័ន្ធ។

ខ្ញុំបន្តះ

«ខ្ញុំចង់និយាយជាមួយ William Cadotte អត់ដឹងគាត់នៅឯណា មានរូបរាងម៉េចទេ»

«អ៊ីចឹង? អញ្ជើញអង្គុយ» គេបានដោះវ៉ែនតាចេញ ហើយរអិលវាចូលក្នុងហោប៉ៅអាវធ្វើការពណ៌ខៀវ បន្ទាប់មកវាយហោប៉ៅនោះថ្នមៗ

«មានគម្រោងចាប់ខ្លួនខ្ញុំ ទាំងមិនដឹងថាខ្ញុំមុខមាត់ម៉េច?»

«មិនយល់ទេ» ខ្ញុំតបភ្លាមនឹងប្រុសស្អាតដោយមិនភ្លេចសួរបន្ថែម «គឺលោក?»

«បាទ»

គេញញឹមបញ្ចេញសម្រស់និងភាពជឿជាក់ល្មមឱ្យខ្ញុំខំអស់ពីសមត្ថភាពដើម្បីធ្វើដូចមិនអើពើនឹងបេះដូងខ្ញុំខ្លួនឯង។

«ហើយ.....អត់ទៅចាប់ឆ្កែចចកសំណព្វទេ?»

«សំណព្វបានទៀត?» ខ្ញុំតបដោយគិតថាគេក៏ដឹងរឿងកញ្ញាឡាសុនស្លាប់និងមហន្តរាយក្នុងសាលាក្មេងៗមិនខាន។  ពិតមែនហើយ គេសួរមកវិញភ្លាមៈ

«ជេស៊ីបានបាញ់គ្រូស្រីហាត់ការម្នាក់នោះ?»

«អត់ទេ» ខ្ញុំតបស្ងៃយប្រវត្តិរួចបន្ថែមឱ្យអស់ចិត្ត «បើមែន ខ្ញុំជាប់ទ្រុងហើយ!»

មាត់របស់គេចំហសម្លឹងខ្ញុំរួចបិទវិញដោយបន្លប់ជាមួយការព្យាយាមយកម្រាមដៃស្តាំប្រាំទៅលូករវែកសក់ដូចសូត្ររបស់គេ។

ខ្ញុំអង្គុយចុះលើកៅអីទល់មុខគេ ទាំងចិត្តមិនស្ងប់ជាមួយបន្ទប់គ្មានខ្យល់អាកាសគ្រប់នេះ។

«តើខ្ញុំជួយអីប៉ូលិសបាន?» គេសួរមកជាលើកទីពីរនិងក្រឡេកមើលអាវយឺតរបស់ខ្ញុំចំកន្លែងប៉ោងទល់។ សង្ឃឹមថាខ្ញុំគិតខុស តែគេដូចជាស្រឡាញ់ដើមទ្រូងខ្ញុំ។ ភ្នែកគេប្រាប់បែបនេះ។

ខ្ញុំត្រូវតែចាក់សំណួរបន្លប់ភាពរំជើបរំជួលៈ

«លោក Will លោកនៅទីនេះក្នុងនាមជាក្របខណ្ឌមន្ត្រីឬជាគ្រូឯកជន?»

ការក្រឡេកមើលដើមទ្រូងរបស់ខ្ញុំ ហាក់ដូចជាមិនបានដកថយសោះតែម្តង។ គេចង់បង្ហាញខ្ញុំត្រង់ៗថា ត្រូវទាញឱ្យថ្លក់នៅនឹងសម្រស់ទីនេះហើយដឹង?

មានអ្វីកើតឡើង???? បុរសៗជាច្រើនប្រហែលជាមិនចាប់អារម្មណ៍នឹងទ្រូងខ្ញុំសោះកន្លងមក ប៉ុន្តែចាប់តាំងពីខ្ញុំចូលវ័យនេះ រឿងនេះបានប្តូរផ្សេង។

ខ្ញុំខ្លួនឯងក៏ពេញចិត្តនឹងសម្រស់ដែលលូតលាស់ នៅក្នុងអាវយឺតរបស់ខ្ញុំដូចគ្នា។ ភ្នែករបស់គេរេមកភ្លាមក៏បានជួបប្រសព្វនឹងភ្នែកខ្ញុំ សង្ឃឹមគេមិនបានឃើញភាពវង្វេងក្នុងបេះដូងខ្ញុំ ដូច្នេះក៏មានតែនិយាយបន្លប់ៈ

«ខ្ញុំមានចម្ងល់ខ្លះ ហើយ....ខ្ញុំត្រូវបានគេប្រាប់ថា ត្រូវមករកលោក Will ជាអ្នកជំនាញដែលស្គាល់របស់នេះ!»

ទាំងខឹងខ្លួនឯងដែលខ្សោយមិនពូកែចៃចង់ប្រុសស្អាត ផ្ទុយទៅវិញ ខ្ញុំបានលូករវយកបន្ទះអលង្ការដែលរើសបាននៅទីកើតហេតុ ចេញពីហោប៉ៅ សម្លឹងវាជាថ្មី ពិតជាមិនខុសទេ មានចម្លាក់ឆ្កែចចកតូចមួយដេកនៅកណ្តាលស្លាកភ្លឺផ្លេក។

មុននឹងខ្ញុំអាចសួរសំណួរមួយបាន គេបានឆក់យកវាទាំងតក់ក្រហល់។

ឱកាសសម្រាប់ការចែចង់ចប់ហើយ។ ឥឡូវនេះជាពេលប្រាកដប្រជា។ លោក Will Cadotte មិនអើពើនឹងទ្រូងខ្ញុំទៀតទេ គេនៅស្លេកស្លាំងសម្លឹងមើលរូបភាពឆ្កែចចកដែលត្រូវបានឆ្លាក់យ៉ាងបុរាណក្នុងរបស់ខ្ញុំយកមកនោះ ហើយបាននិយាយរអ៊ូរទាំចុះឡើង និងសរសេរកំណត់ចំណាំនៅលើក្រដាសសៀវភៅកំណត់ហេតុរបស់គេទៀត។

«មានរឿងអី?»

ខ្ញុំអង្គុយលើកៅអីតែមួយហើយសួរទាំងចំហមាត់ និងមានតែអត់ធ្មត់រង់ចាំ។ ពេលខ្ញុំរង់ចាំ ខ្ញុំក៏បានលបមើលចង្កេះធំរបស់គាត់ លបមើលហួសទៅក្រោមនោះ ខ្ញុំមិនអាចជួយខ្លួនឯងបានទេថា ប្រសិនបើបានរូបរាងនេះមកគ្របពីលើ? ឬខ្ញុំនៅក្នុងរង្វង់ដៃគេ?

សម្លៀកបំពាក់គេ មិនដូចគ្រូបង្រៀនដទៃដែលប៉ូលិសស្រីដាច់ដាបដូចខ្ញុំតែងលបចំណាំទេ។ ហើយក៏មិនដែលមានអ្នកណាមកបង្រៀនមហាវិទ្យាល័យពាក់ក្រវិលមួយចំហៀងដូចគេនេះដែរ។ គេយូលណាស់និងស៊ិចទៀត។

ប្រហែលជាដប់ប្រាំនាទីបានកន្លងផុតទៅ មុនពេលដែលគេព្រមត្រលប់មកគិតថា មានខ្ញុំកំពុងចាំចម្លើយក្នុងបន្ទប់នេះ។

គេក្រឡេកមើល ខ្ញុំទាំងព្រេចភ្នែកមមីរ ដូចជាមិនយល់ពីអារម្មណ៍សម្ងាត់?

«អ្នកស្រីប៉ូលិសបានរបស់នេះមកពីណា?"

«ខ្ញុំគិតថា ខ្ញុំកំពុងជាអ្នកសួរសំណួរ?»

«ខ្ញុំមិនឆ្លើយ រហូតដល់ហាន់នីប៉ូលីសឆ្លើយសំណួរខ្ញុំអស់សិន»

ពាក្យហាន់នីដូចពីរោះ ខ្ញុំស្តាប់ហើយមិនរឹងត្អឹងទេ។ ខ្ញុំព្រមនិយាយ៖

«រើសបានលើភ្នំ កណ្តាលផ្លូវហាយវេមួយ-កៅសិបប្រាំបួន។»

គេនៅតែចោលភ្នែកមកបែបងឿងឆ្ងល់៖

«ឱ្យច្បាស់បន្តិច ខ្ញុំនៅមិនយល់ទេ»

«កន្លែងឡាសុនមានគ្រោះថ្នាក់ក្បែរៗនោះ!»

«ជាមួយចចក?» ការសម្លឹងរបស់គេពេលនេះភ្លឺមុតស្រួច ដូចនឹងសំឡេងគ្រលរបស់គេដែរ។

«ចាស៎»

ភ្នែករបស់គេនេះផ្លាស់ទីចុះឡើង ក្នុងន័យផ្តោតគិតអ្វីមួយយ៉ាងជ្រៅ ដូច្នេះខ្ញុំបានសំងំទុកពេលឱ្យគិតបានយូរតាមដែលអាចធ្វើទៅបាន។ ជាការពិតណាស់វាមិនយូរប៉ុន្មានទេ។

«ម៉េចដែរ?» ទីបំផុតខ្ញុំសួរ ដែលសំឡេងខ្ញុំនាំគេវិលត្រលប់មកកន្លែងនេះវិញ។

«អាចប្រាប់ខ្ញុំបានឬនៅ ថានេះជាអ្វី? តើអ្នកណាអាចជាម្ចាស់របស់នេះ? តម្រុយណាមួយពាក់ព័ន្ធនឹងចចក?»

«កម្មសិទ្ធិនៃ Ojibwe មនុស្សចចក!»

ខ្ញុំក្រពាត់ដៃផ្អែកខ្នង។ ចម្លើយនេះត្រូវនឹងការគិតសង្ស័យពេញមួយយប់មកហើយ។

«ហាន់នី នាងអាចមានបញ្ហាព្រោះអ្នកដែលបាត់វាប្រហែលជារកគ្រប់វិធីក្នុងការដណ្តើមយកវិញ»

ខ្ញុំញញឹមឌឺះ

«ហេតុអ្វី? ខ្លាចប៉ូលិសនាំខ្លួនរឿងអ្នកស្លាប់ឈ្មោះឡាសុន?»

«មិនមែនទេ! ពួកគេឯណាខ្លាចប៉ូលិស! តែរបស់នេះជាអំណាច! វាអាចជួយការពារគ្រួសារ ជាអំណាចខាងវិញ្ញាណ វេទមន្ត»

«វ៉ូ-វ៉ូ?» ខ្ញុំរអ៊ូដោតបញ្ចេញអាការៈរិះគន់ស្អប់ woo-woo (ជំនឿអាគមខ្មៅដែលល្បីសុសសាយតំបន់នេះក្នុងចំណោមចាស់ស្រុក)។ គេក្រឡេកមើលអាការៈខ្ញុំដឹងបានភ្លាមនិងស៊កសួរបកមករហ័សៈ

«ដូចមិនជឿ?»

«ថ្មវេទមន្តនិងវិញ្ញាណចចក? អូព្រះ»

William Cadotte មិនខឹង គេគ្រាន់តែឱនមុខបន្តិចនឹងលបញញឹម។ គេបានរកឃើញថា ខ្ញុំមានៈគួរឱ្យអស់សំណើច ដូចជាកូនក្មេង រឹងទទឹង?

«ជំនឿគឺ.....ពិបាកល្ងីល្ងើទៅព្រមជឿណាស់សាស្ត្រាចារ្យ Will អើយរឿងមនុស្សចចកខែពេញបូណ៌មីអីអស់នេះ»

គេមិនខឹងដដែល។ ខ្ញុំចាំបានថា កាលនៅពីក្មេង ខ្ញុំបានចំណាយពេលរាប់ម៉ោងអធិស្ឋានសុំចក្រវាឡ ឱ្យប៉ាខ្ញុំវិលមកផ្ទះវិញ។ តែគាត់ដែលបង្ហាញស្រមោលទេ។ ខ្ញុំលែងជឿអព្ភូតហេតុនិងរឿង

អច្ឆរិយៈក្នុងប្រលោមលោកជាយូរណាស់មកហើយ។

តែបុរសនេះលូកមាត់មកនិយាយខ្សឹបៗ៖

«ស្រីស្អាតនឹងឃើញការពិតឆាប់ៗ»

ខ្ញុំជឿលើអ្វីមួយផ្អែកលើការពិត ខ្ញុំចង់បញ្ជាក់ពាក្យនេះ តែខ្ជិលនិយាយ។ ការប្តូរមករស់នៅកណ្តាលទឹកដី woo-woo មួយនេះ បានបង្រៀនខ្ញុំយ៉ាងរហ័សថា ទៅមានៈឈ្លោះជាមួយនរណាម្នាក់ដែលមានជំនឿអាគមងងឹត ដូចជាការវាយក្បាលរបស់ខ្លួន ទៅនឹងជញ្ជាំងឥដ្ឋឱ្យឈឺឥតន័យ។

«ខ្ញុំស្គាល់ត្រកូលចចកមួយចំនួនក្នុងតំបន់នេះដេស៊ី»

ខ្ញុំសើចរលាក់បន្តិចហើយមិនអាចទប់បានខ្ញុំខ្ទប់មាត់ដែលអស់សំណើច ស្រាប់តែគេឆ្លើយឡើងទៀតក្នុងសព្ទស្រទន់៖

«ព្រោះខ្ញុំក៏ជាម្នាក់ដែរក្នុងចំណោមពួកគេអូនសម្លាញ់»

គេឆ្លើយដ៏អស្ចារ្យ។ ទោះបីខ្ញុំមានការសង្ស័យលើរឿងគ្រប់យ៉ាងក៏ដោយ។